# សីលធម៌

រៀបរៀងដោយលោក យ៉ែម-សោម

ចៅហ្វាយស្រុកវើត្រែត

ឧបាសិកា យ៉ែម-សារិន ជាកូនប្បង

បោះពុម្ពបែកជាធម្មទាន

ក្នុងឱកាសបុណ្យឆ្លង បើរមន្ទីរប្មិ ១ ខ្នង

នៅវត្តពោធិលង្កាក្រៅ

ឃុំ-ស្រុក-ខេត្ត-សៀមរាប

ព. ស. ២៥០៤ គ. ស. ១៩៦១

CA 42

# សីលធម៌

រៀបរៀងដោយលោក យ៉ែម-ដោម

ចៅហ្វាយស្រុករ៉ើត្រែត

ឧបាសិកា យ៉ែម-សារិន ជាកូនច្បង

បោះពុម្ពចែកជាធម្មទាន
ក្នុងឱកាសបុណ្យឆ្លង បេរមន្ទីរឬ ១ ខ្នង

នៅវត្តពោធិលង្កាក្រៅ
ឃុំ-ស្រុក-ខេត្ត-សៀមរាប

ព. ស. ២៥០៤ គ. ស. ១៩៦១



ឆាយាលក្ខណ៍

ព្រះវិន័យធរ គ ណ ច័ន្ទ - ឡុង

ចៅអធិការ វត្តពោធិលង្ការក្រៅ

ឃុំ – ស្រុក – ខេត្ត – សៀមរាប

ជន្មាយុ ៦៣ ឆ្នាំ



ឆាយាលក្ខណ៍

ឧបាសិកា យ៉េម សារិន ជន្មាយុ ៥១ ឆ្នាំ

ដែលស្លាបនា ថេរមន្ទីរនៅវត្ត ពោធិលង្កាក្រាវ

ឃុំ–ស្រុក ខេត្តសៀមរាប



មើលពីឆ្វេងទៅស្តាំ

ខាងឆ្វេង ឧបដ្ឋានសាលា ទំហំប៉ុនគ្នា ខាងស្តាំ

ថេរមន្ទីរទទឹង ៨ ម៉ែ០០ បណ្តោយ ២០ម៉ែ០០ ដែលឧបាសិកា

យ៉ែម-សារិន ស្លាបនាហើយធ្វើបុណ្យឆ្លង

ពីឆ្នាំ ១៩៦១

# អារម្ភកថា

សៀវភៅ សីលធម៌ នេះខ្ញុំព្រះករុណា នាងខ្ញុំនាម យ៉ែម សារិន ជាឧបាសិកា វត្តពោធិសង្ហាក្រៅ ឃុំ-ស្រុក ខេត្ត សៀមរាប,

បានពឹងលោក យ៉ែម.ដោម ចៅហ្វាយស្រុករើត្រែត ជាបិតា ឲ្យលោករៀបរៀងចែកទាន លោកក៏បានរៀបរៀងរួច ហើយ មើលឲ្យស្តាប់ ខ្ញុំព្រះករុណានាងខ្ញុំមានសេចក្តីពេញចិត្ត ប្រាថ្នាបោះពុម្ពចែកជាធម្មទាន ក្នុងឱកាសធ្វើបុណ្យឆ្លងបេរមន្ទីរ ១ ខ្នងនៅក្នុងវត្ត ពោធិសង្ហាក្រៅ ខេត្តសៀមរាប, លោក ក៏ប្រាប់ថា ត្រូវយកសៀវភៅធម៌នេះ ទៅប្រគេនព្រះតេជព្រះ គុណ ធម្មិស្សរោ ឯក.ញឹម នៅវត្តពិភទ្វរង្សី សង្កាត់លេខ ២ ក្រុងភ្នំពេញ ពិនិត្យបាលី នឹងសេចក្តីធម៌ ព្រមទាំងកែអក្សរ ខុស ត្រូវជាមុនសិន ហើយសឹមបោះពុម្ពចែកជាខាងក្រោយ ខ្ញុំ ព្រះករុណា នាងខ្ញុំ ក៏បាននាំយកសៀវភៅធម៌នេះ ទៅប្រគេន ព្រះតេជព្រះគុណ ធម្មិស្សរោ តាមបង្គាប់បិតា ព្រះគុណអង្គ នោះ លោកមានព្រះហឫទ័យមេត្តាជួយ ឧបត្ថម្ភកិច្ចគ្រប់យ៉ាង

ដរាបដល់បានសំរេចជាសៀវភៅនេះឡើង ។

## អំពីបុញ្ញកិរិយាវត្ថុចំពោះខ្លួន

១- ខ្ញុំបានថ្វាយខ្លួនជាឧបាសិកា តាំងពីឆ្នាំរក មកដល់ឆ្នាំឆ្លូវត្រីស័ក ព.ស. ២៥០៤ គ.ស ១៩៦១ នេះបាន៣០ឆ្នាំហើយ ។

២- ខ្ញុំបានសាង ព្រះពុទ្ធរូបមាសសុទ្ធ ១អង្គ ប្រាក់ ១អង្គ កែវ ១អង្គ ប្រាក់ស៊ិន ៣ អង្គ រួមជា ៦ ព្រះអង្គ

៣- ខ្ញុំបានស្ថាបនា ធាដ្ឋា១ខ្នង សាលាភាដ្ឋា១ខ្នង កុដិតូច១ខ្នង ពីគ្រឿងឈើប្រកក្បឿង និង អណ្តូងទឹកដាក់លូស៊ីម៉ងត៍ ១ និងបេរមន្ទីរបីថ្មី ១ទទឹង ៨ម,០០ បណ្តោយ ២០ម,០០ ព្រមទាំងគ្រឿងសម្ភារៈ ផ្សេងៗ មាន ទូតុកៅអី គ្រែពូកកន្ទើយកន្ទេលមុង និង ចាន-ឆ្នាំង ជាដើម ។

ឯបេរមន្ទីរនោះស្ថាបនា ដោយមានពុទ្ធបរិស័ទច្រើនគ្នាចូលជួយជាមួយផង ដើម្បីទុកសម្រាប់ព្រះថេរៈទាំងឡាយដែលឡើងទៅជាចៅអធិការគង់ មានព្រះតេជព្រះគុណ ព្រះវិន័យធរគណ ព្រះនាម ចន្ទ-ឡុន ចៅអធិការបច្ចុប្បន្នសព្វថ្ងៃនេះជាដើម ។

# អំពីបច្ច័យស្ថាបនាថេរមន្ទីរ

១- ខ្ញុំព្រះករុណា នាងខ្ញុំ បានដាក់ផ្ទះឈើ១ខ្នងតម្លៃ ៤០.០០០៛០០ វេរប្រគេនព្រះសង្ឃរូប តមកបានផ្តើមកសាងជាបេរមន្ទីរប្ញើទំហំទទឹង ៨ម,០០ បណ្តោយ២០ម ០០ មានព្រមទាំងបន្ទប់ស្រង់ទឹក និងបន្ទប់សម្រាប់បន្ទោបង់នូវឧច្ចារបស្សាវៈផង, ព្រមទាំងគ្រឿងសម្ភារៈផ្សេងៗ ឯទៀតផង ។

២ - ការស្ថាបនានោះ បានព្រះតេជព្រះគុណព្រះវិន័យធរគណព្រះនាម ច័ន្ទ-ឡុង និងលោកអាចារ្យវត្ត ២ នាក់ មានលោកអាចារ្យ មាស, ថ្លាង ជាដើមជាទីប្រឹក្សា និងជួយជាកម្លាំងបាត់ការគ្រប់យ៉ាង ក្នុងការស្ថាបនាបេរមន្ទីរនេះ ។

៣- លោក យ៉ែម-សារឿន ចៅហ្វាយខេត្តកំពង់ធំ ព្រមទាំងសហការី និងមិត្តទាំងឡាយរបស់លោក ធ្វើជាកឋិនហែរមកជួយរួមបច្ច័យជំនួយក្នុងបុណ្យនោះបាន ៥០,១០០៛០០

៤- លោក យ៉ែម-ដោម ចៅហ្វាយស្រុកវើត្រែតជាបិតាបួស ១.០០០៛០០ ។

www.sangharakkhaka.com

៥- ឧបាសិកា ស-អ៊ន់ សៀមរាប ១០,០០០រ០០ ។

៦- លោក ហ៊ុយ . ម៉ោង អតីតចៅហ្វាយខេត្តសៀមរាបចូលរួមគ្នា ២១,០០០ ដុំ ។

៧- លោកយាយឧបាសិកា ហ៊ុម និងលោកយាយឧបាសិកា ម៉ុន ព្រមទាំងពុទ្ធបរិស័ទច្រើនគ្នាបានផ្ញើជាកប្បិយវត្ថុមកជួយសាងបារមីនេះផងដែរ សូមអភ័យទោសអំពីសំណាក់លោកអ្នកដែលខ្ញុំរាប់ឈ្មោះពុំបានអស់សព្វគ្រប់ក្នុងទីនេះ តពីនោះមកខ្ញុំព្រះករុណា នាងខ្ញុំ ប្រឹងតែខំប្រឹងគិតរៃលករកបច្ច័យផ្សេងៗក្នុងការសាងបារមីនេះ ដរាបដល់បានសំរេច ធ្វើបុណ្យឆ្លងក្នុងថ្ងៃនេះឯង ។

## ឧទ្ទិសកថា ពាក្យឧទ្ទិសផល

នៅទីបំផុតនៃការរៀបរាប់នេះ ខ្ញុំព្រះករុណា នាងខ្ញុំ សូមរួបរួមបុញ្ញរាសី ដែលកើតឡើងអំពីបុណ្យអាមិសទាន និងធម្មទាន ឧទ្ទិសជូនចំពោះលោកអ្នកមានគុណទាំងឡាយ ដែលបែកឆ្ងាយទៅហើយក្តី រស់នៅឡើយក្តី គឺ

១- ជូនលោកបិតា នាម យ៉េម-ដោម ចៅហ្វាយស្រុក-

វិគ្រោត របស់នៅសព្វថ្ងៃ ។

២ – ជូនលោកមាតា នាម ប៉ែន.ស្រួយ ទទួលមរណៈ-ភាពទៅយូរឆ្នាំហើយ,

៣ – ជូនលោកជីតា នាម ប៉ែន ទទួលអនិច្ចកម្មទៅយូរឆ្នាំហើយ,

៤ – ជូនលោកជីដូន នាម ផៃ ទទួលអនិច្ចកម្មទៅយូរឆ្នាំហើយ,

៥ – ជូនអ្នក ឧុន.គៀយ ជាស្វាមី ទទួលអនិច្ចកម្មទៅយូរឆ្នាំហើយ ។

៦ – ជូនលោកឪពុកធំ លោកម្ដាយធំ នឹងមារ-មីង ព្រមទាំងបងប្អូនញាតិសាលោហិតជិតឆ្ងាយទូទៅទាំង ៧ សន្តាន ។

៧ – ជូនដល់លោក-អ្នកសប្បុរសទាំងឡាយ ដែលបានជួយខ្វល់ខ្វាយ ដោយកម្លាំងកាយក្ដី ដោយកម្លាំងធនធានក្ដីគ្រប់ហាន: ។

៨- ជូនដល់ទេវតាទាំងឡាយ ជាសម្មតិទេពក្តី ជាឧប្បត្តិទេពក្តីទូរទៅគ្រប់ជាន់ថ្នាក់ សូមឲ្យអស់លោក-អ្នកនាងទាំងឡាយនោះៗ បានទទួលភាគឧត្តមផលដ៏ប្រសើរក្នុងបុណ្យនេះ ដោយឥដ្ឋមនុញ្ញផលវិបុលសុខគ្រប់ប្រការ ឲ្យបានស្មើៗគ្មានឯនាងខ្ពង់ទាបខាងឡើយ ។

ថ្ងៃអង្គារ ១៤ កើត ខែកត្តិក ឆ្នាំឆ្លូវត្រីស័ក ព.ស. ២៥០៤

ឧបាសិកា

**យ៉េម-សារិន**

# សីលធម៌

www.ameriquekhmer.fr

សំដែង អំពីធម៌ជាគ្រឿងដុះខឿនចិត្ត ក្នុងវិធីរក្សា សីលធម៌ពុទ្ធបញ្ញត្តិ ផ្នែកវិន័យដែលជាគ្រឿងការពារលោកទូទៅៗ

ក្នុងខាងដើមនេះ នឹងពណ៌នាគុណនៃព្រះពុទ្ធសាសនា ដោយសង្ខេប ដើម្បីបានបង្អូរទឹកចិត្តនៃកុលបុត្រអ្នកមានសទ្ធា ក្នុងព្រះពុទ្ធសាសនា ឲ្យយាងចុះកាន់ សីលធម៌ មានចិត្តជឿជាក់ក្នុងគុណ ព្រះរតនត្រ័យប្រកបដោយកុសលចេតនាដែលដុសខ្លៀងប្រាថ្នាប្រារព្ធនមស្សការថ្វាយបង្គំ ព្រះរតនត្រ័យនោះនឹងរក្សា សីលធម៌ ដែលជាទីពឹងដ៏ប្រសើររបស់ខ្លួន ដោយគោរព ។

ពុទ្ធបរិស័ទទាំងឡាយ ក្នុងសីល៥ ដែលលោកបានជ្រាបខ្លះហើយនោះ វេលានេះយើងត្រូវតែពិនិត្យឲ្យរឹតតែច្បាស់ឡើងៗ ក្នុងការប្រព្រឹត្តមិនឲ្យខុសបាកខ្សែ សីលធម៌ ពាក្យថាសីល៥នោះបានដល់សិក្ខាបទ៥ ដូចមានបាលី ក្នុងសង្គីតិសូត្រ គម្ពីរទីឃនិកាយ បាដិកវគ្គថា បញ្ច សិក្ខាបទានិ បញ្ចៈ ប្រែថា៥ សិក្ខាបទានិ ប្រែថា សិក្ខាបទទាំងឡាយ បញ្ចសិក្ខាបទានិ

ប្រែថាសិក្ខាបទទាំងឡាយ ៥ គឺ បាណាតិបាត វៀរសម្លាប់សត្វ ១ អទិន្នាទាន វៀរលួចទ្រព្យអ្នកដទៃ ១ កាមេសុមិច្ឆាចារៈ វៀរប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ មុសាវាទៈ វៀរពោលពាក្យកុហក ១ សុរាមេរយៈ វៀរផឹកទឹកស្រវឹងគឺសុរានឹងមេរយ័ ១ សិក្ខាបទទាំង ៥ យ៉ាងនេះ កាលបើបុគ្គលរក្សាដោយចេតនាជាអកុសលលោកហៅថា អកុសលធម៌ សិក្ខាបទទាំង ៥ នេះ លោកទុកជាបន្ទាត់ ៥ សម្រាប់ផ្ទៀងចិត្តអ្នកកាន់ព្រះពុទ្ធសាសនាផង ជាបុព្វសិក្ខារបស់ពុទ្ធបរិស័ទទាំងឡាយផង

កាលបើសីល ៥ បរិសុទ្ធស្អាតល្អហើយ នឹងឈានឡើងកាំទៅកាន់សីល ៨ គឺ ឧបោសថសីល ក៏ឡើងបានដោយការប្រតិបត្តិ បំពោះចិត្តតែមួយ ៗ អត្តបទតទៅនេះ នឹងសំដែងអំពីការវៀរតាមពុទ្ធប្បញ្ញត្តិ ក្នុងអង្គសីល ៥ តាមបាលីថា វិរតិនោះបានដល់ការវៀរ ពាក្យថាវៀរនោះ គឺ វិរតិចេតនា ប្រកបដោយកុសលចិត្តរបស់មនុស្សដែលកើតឡើងដោយខ្លួនឯង មិនមានអ្នកដះទឿនឡើយ ៗ

វិរតិនោះលោកចែកជា ៣ ប្រការ គឺសម្បត្តវិរតិ ១ សមាទានវិរតិ ១ សមុច្ឆេទវិរតិ ១ (រួមជា៣ប្រការ)

អត្ថបទទី១ សម្បត្តវិរតិ បានដល់ការវៀរបស់មនុស្ស ដែលនៅពុំទាន់បានបេរកាយថ្វាយខ្លួន ដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទាំងពុំទាន់បានសមាទានសិក្ខាបទ ហើយមិនបាន ប្រព្រឹត្តកន្លងនូវវត្ថុនោះ ៗ គឺមិនប្រព្រឹត្តកន្លងវត្ថុ ដែលមាន មកដល់ក្នុងទីចំពោះមុខ ឬកំបាំងមុខ ។

ឧទាហរណ៍ដូចឃើញត្រីនៅក្នុងថ្លុក មានទឹកតិច គួរ សម្លាប់យកធ្វើជាអាហារបាន ហើយមិនសម្លាប់ ឃើញទ្រព្យគេ គួរបន្លំលួចយកបានហើយមិនបន្លំលួចជាដើម ដោយពិចារណា ឃើញជាតិរបស់ខ្លួននឹងសេចក្ដីបេះដឹងកើតឡើងខ្លួនឯងថា: អំពើរសម្លាប់សត្វ នឹងលួចទ្រព្យគេជាដើមនេះ ជាអំពើរទុច្ចរិតអាក្រក់ក្រៃ ជាគ្រឿងនាំមកនូវទោសទុក្ខគ្រប់យ៉ាង ក្នុងលោកនេះ នឹងលោកខាងមុខរកទីបំផុតគ្មាន អាត្មាអញមិនគួរធ្វើឡើយ យ៉ាងនេះឈ្មោះថា សម្បត្តវិរតិ ជាវិរតិសីលកើតឡើងដោយ

ខ្លួនឯង តួយ៉ាងដូច ចក្ខុបាលៈឧបាសក១នាក់ នៅគរលង្កាទ្វីប មានសេចក្ដីដំណាលថា មាតាឧបាសកនោះមានជម្ងឺ គ្រូពេទ្យគេពិនិត្យរោគរូបហើយគេប្រាប់ថា ត្រូវផ្សំថ្នាំនឹងសាច់ទន្សាយស្រស់ បក្កុនឧបាសកនោះ ក៏ខំដើរទៅរកទន្សាយឯស្រុកស្រែ ក្នុងសម័យនោះបក្កុនឧបាសកកំពុងដើរ មានសត្វទន្សាយមួយក្រឡេកឃើញមនុស្ស ហើយខំស្ទុះរត់បោលយ៉ាងខ្លាំង លុះលោតទៅក៏ជាប់ខ្លួននៅនឹងប្រគាប់ឈើ បីដូចជាគេចាប់ទុក ទន្សាយនោះខំកន្ត្រោងរើមិនរួច ភ័យខ្លាំងណាស់ហើយស្រែកយំដោយសម្លេងថា "ករិ ករិ" ឯចក្ខុបាលៈឧបាសក លុះបានឮសម្លេងសត្វទន្សាយនោះស្រែក ក៏ស្ទុះទៅចាប់បានទន្សាយនោះហើយគិតថានឹងសម្លាប់យកសាច់ធ្វើថ្នាំដល់មាតាឲ្យជារោគនោះ សត្វទន្សាយរិតតែភ័យខ្លាំងខំស្រែកផងទាក់ផង ឧបាសកនោះក៏គិតថា ឱ! សត្វទន្សាយនេះស្រែកយំភ័យភាន់ភាំងតក់ស្លុតញ័ររន្ធត់អស់ទាំងខ្លួនខ្លាចសេចក្ដីស្លាប់ ក៏លែងសត្វទន្សាយនោះទៅ យ៉ាងនេះឈ្មោះថា សម្បត្តវិរតិ គឺចិត្តតាំង

វៀរចាកការសម្លាប់កើតឡើងដោយខ្លួនឯង គួរយល់បានដោយសេចក្ដីសង្ខេបប៉ុណ្ណេះ ។

## សំដែងអំពីសិក្ខាបទ

សិក្ខាបទ ទី២ ទី៣ ទី៥ មិនបានអធិប្បាយប្រាប់គ្រប់សិក្ខាបទនោះទេ, នឹងអធិប្បាយតែអំពីសិក្ខាបទ ទី៤ ជូនលោកអ្នករក្សាសីលស្ដាប់ ព្រោះអត្ថបទក្នុងសីល ទី៤ នេះ នឹងយល់បានដោយកម្រ ប្រព្រឹត្តបានក៏ដោយកម្រ មកពីមិនដឹងលក្ខណសីល នឹងមិនពេះប្រយ័តបិត្ត ។

សិក្ខាបទទី៤ ហាមមិនឲ្យនិយាយខុស កិរិយាដែលនិយាយពាក្យខុសចាកសេចក្ដីពិត ឈ្មោះថា មុសាវាទ សិក្ខាបទនេះព្រះអង្គទ្រង់បញ្ញត្តិឡើង ដើម្បីឃាត់ហាមបុគ្គលគ្រប់ជាន់ថ្នាក់ កុំឲ្យកាត់ប្រយោជន៍ដល់គ្នានឹងគ្នា ព្រោះធម្មតារបស់មនុស្សដែលនៅរួមគ្នា ដោយសេចក្ដីសាមគ្គីមូលមិត្តបិត្តកំនិតជាមួយគ្នា ជាទីគោរពរាប់អានដល់គ្នានឹងគ្នា បើនឹងប្រកបការអ្វីមួយជាមួយគ្នាក្ដីនិយាយសាកសួរគ្នាពីការអ្វីក្ដី ត្រូវនិយាយស៊ី

ឲ្យប្រាកដទៅតាមការពិតការមែន ជាបើអ្នកម្ខាងពោលពាក្យមិនពិត មានចិត្តមិនស្មោះត្រង់ដល់គ្នានឹងគ្នាហើយ មិនជាទីទុកចិត្តគ្នាយ៉ាងនេះហើយ សាមគ្គីធម៌ក៏បែកទាំងរូបកាយក៏បែកឃ្លាតឆ្ងាយពីគ្នា បើខ្លួនជាអ្នកធំគេធ្លាប់គោរពរាប់អាន ក៏ដាច់ជាកការគោរពរាប់អានគ្នា ព្រោះកិរិយានិយាយពាក្យមិនពិតទាំងកាត់បង់ប្រយោជន៍យ៉ាងច្រើន ព្រោះធ្វើឲ្យគេយល់ចិត្តខុស។

ហេតុដូច្នេះមនុស្ស ដែលមានសេចក្ដីសាមគ្គីនៅរួមគ្នាជាមិត្ត ត្រូវតែមានចិត្តស្មោះត្រង់នឹងគ្នាទុកជាបង្គោលជាទីតាំងមាំកុំពោលពាក្យមិនពិតទើបរក្សាចិត្តគ្នា រក្សាសាមគ្គីធម៌តាំងនៅដោយល្អបាន កាលបើសាមគ្គីធម៌មានហើយ សេចក្ដីសុខ-ចំរើនក៏កើតឡើងជាលំដាប់គ្នាបាន មកពីពោលពាក្យពិត មកពីមានការទុកចិត្តគ្នា ។

**អំពីពោលពាក្យមុសាវាទ លោកចាត់ជា ៣ យ៉ាងគឺ**

មុសាវាទ១ អនុលោមមុសាវាទ១ បដិរូបមុសាវាទ១

ដូចអធិប្បាយតទៅនេះ កិរិយាដែលពោលពាក្យឲ្យខុស ចាកសេចក្ដីពិត ដោយចេតនាចង់ឲ្យគេយល់ចិត្តខុស ឈ្មោះថា

មុសាវាទ ជាវាចាកាត់ផ្តាច់បង់នូវប្រយោជន៍របស់ អ្នកដទៃ
វត្ថុ ប្រែថារបស់ឬរឿងរ៉ាវអ្វីមួយ បើអ្នកនិយាយមានចេតនា
បំណងនឹងនិយាយឲ្យខុសចាកសេចក្តីពិត្យ ឬបង្ហាញកិរិយាតាម
ទ្វារកាយជាកាយវិការផ្សេងៗមានក្តាប់ដៃជាដើម ឬក៏សរសេរ
នៅសេចក្តីមិនពិត្យតាមសំបុត្រឲ្យគេមើលក្តី បើអ្នកស្តាប់ដឹង
សេចក្តីច្បាស់ចូលចិត្តជឿតាមពាក្យសំដី ដែលខ្លួននិយាយបាន
ក្តី ឬដឹងជឿតាមអាការកិរិយាដែលខ្លួនបង្ហាញគេក្តី ចាត់ជា
មុសាវាទ ឯវត្ថុគឺរឿងរ៉ាវមិនពិត្យ ទោះបីគេជឿក្តី គេមិនជឿក្តី
គេដឹងសេចក្តីនោះច្បាស់ក្តី មិនបានដឹងច្បាស់ក្តីចាត់ជា អង្គ
មុសាវាទ សៅហ្មងសីល បើអ្នកស្តាប់ៗមិនដឹងរឿង ឬគេ
មិនបានជាឮ មិនចាត់ជាមុសាវាទដោយន័យនេះទេ មុសាវាទ
ជាវចីកម្ម សំរេចការបានដោយផ្លូវវាចា បានដល់ការក្លែង
និយាយកុហកដោយវាចា ដូចជាវត្ថុណាដែលខ្លួនឃើញខ្លួន
ដឹង លុះមានគេសួរឆ្លើយប្រាប់គេថាវត្ថុនោះខ្លួនមិនឃើញមិន
ដឹង ដូចន័យនេះឈ្មោះថា មុសាវាទ ដោយផ្លូវវាចាចាត់ជា
វចីទ្វារវចីកម្ម ក្នុងកម្មបថ ១០ ។

មុសា ផ្លូវកាយ បានដល់ការសំដែងអាការៈឲ្យគេដឹងដោយកាយដូចជារិត្តដែលខ្លួនឃើញខ្លួនដឹងនោះ លុះមានគេសួរខ្លួនក្រវីក្បាលឬរាដៃឬក៏បោកដៃជាដើម ដែលជាគ្រឿងបដិ-សេធន៍ឲ្យគេដឹង គេនឹងសំគាល់ថាខ្លួនមិនដឹងមែន ឈ្មោះថាមុសាផ្លូវកាយ ចាត់ជាកាយទ្វារិកកម្ម ក្នុងកម្មបថ, ន័យនេះគួរឲ្យឈ្មោះថា បដិសេធមុសាវាទ ។

មុសាវាទ ជាសេចក្ដីបញ្ញត្តិហាមឃាត់ដល់ការធ្វើសីលមិនឲ្យធ្លុះធ្លាយ ឬសៅហ្មងជាដើម ក្នុងសិក្ខាបទនេះ ពុទ្ធបំណងចង់ឲ្យនិយាយតែពាក្យពិតពាក្យមែនពាក្យមានប្រយោជន៍ដល់អ្នកស្ដាប់ ។

អ្នកនិយាយពាក្យមិនពិតដោយមានចេតនាចង់ឲ្យគេជឿខុសចាត់ជាមុសាវាទ ដូចអ្នកសួរខ្សែក្រវ៉ាត់ស្ពាន់ស្មានថាមាស អ្នកដឹងច្បាស់ដែរ ប៉ុន្តែឆ្លើយបន្លំបណ្ដោយថាអើមាសហើយហ្នឹង ចាត់ជាអនុលោមមុសាវាទ, បើអ្នកសួរមកខ្លួនៗ ដឹងហើយ ប៉ុន្តែក្រវីក្បាលឲ្យសញ្ញាថាមិនដឹង ចាត់ជាបដិសេធមុសាវាទ

បើអ្នកនិយាយរឿងព្រេងឲ្យគេស្ដាប់ ឬនិយាយប្រឡីពាក្យ

ប្រទូំឈ្មោះដោយគ្មានចេតនាបង់ឲ្យគេជឿខុស មិនបាត់ជាមុសាវាទបានឡើយ ។

## សមាទានវិរតិ

សមាទានវិរតិ ដែលកើតឡើងដល់បុគ្គលអ្នកបានសមាទានសិក្ខាបទមានសីល ៥ ជាដើមផ្ទាល់អំពីព្រះសង្ឃ ទាំងបានថ្វាយខ្លួនបំពោះព្រះរតនត្រៃ ទទួលថាជាឧបាសក ឬជាឧបាសិកា ក្នុងព្រះពុទ្ធសាសនា ហើយតាមបម្រាមក្នុងសិក្ខាបទនោះៗ បើតាំងខ្លួនជាសិស្សព្រះរតនៈត្រៃ ហៅថា សិស្សកាវូបគមនៈ បើតាំងចិត្តទុកជាធ្វើការអ្វីត្រូវយកព្រះរតនៈត្រ័យជាទីពឹងប្រព្រឹត្តទៅខាងមុខ ហៅថា តប្បរាយនតា បើតាំងចិត្តទុកមាំថា ស៊ូលះបង់ជីវិតខ្លួន មិនព្រមលះបង់ព្រះរតនៈត្រ័យ ឬមិនព្រមលះបង់ជីវិតសីល គឺមិនព្រមសម្លាប់សត្វ មិនព្រមលួចទ្រព្យគេជាដើមឡើយ យ៉ាងនេះហៅថា អត្តសន្និយាតន (ល) ពោលមកក្នុងបទសមាទានវិរតិនេះ ចប់ដោយសង្ខេបប៉ុណ្ណោះ ។

ឯ សមុច្ឆេទវិរតិ បានដល់ព្រះអរិយបុគ្គលដែលលោកលះបង់កិលេសជាសមុច្ឆេទបហារ ។ល។

# ព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនា ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ត្រាស់ទុកថា សីល ជាគ្រឿងរក្សាកាយនិងវាចា ឲ្យមានសណ្ដាប់ធ្នាប់ ឲ្យមានរបៀបរៀបរយល្អ ដើម្បីការពារលោកកុំឲ្យគេតិះដៀលលើកទោស, សមាធិ ជាគ្រឿងធ្វើចិត្តឲ្យស្ងប់រម្ងាប់ រក្សាចិត្តឲ្យនឹងនៅក្នុងអារម្មណ៍តែ ១ ដែលជាកុសលធ្វើចិត្តកុំឲ្យច្រួលច្របល់ទៅក្នុងកាម បញ្ញា លាងសំអាតចិត្តឲ្យថ្លាបរិសុទ្ធស្អាតផូរផង់ មិនឲ្យមានការសៅហ្មងប្រឡាក់ដោយធូលីគឺកិលេស ជាពិសេសបញ្ញានេះជ្រោមជ្រែងចិត្តពីល្ងង់ទៅបេះពីអាក្រក់ទៅល្អ ពីគ្មានសីលធម៌ទៅមានសីលធម៌ ពីគ្មានមគ្គផលនិព្វានទៅមានមគ្គផលព្រះនិព្វាន បំព្រួញឲ្យសេចក្ដីថាព្រះពុទ្ធសាសនា ជាគ្រឿងលះលោកជាធម៌ជួយគាំនឹងលោកនាំចិត្តសត្វឲ្យលះអាល័យលោកទៅរកទីផុតទុក្ខគឺព្រះនិព្វាន ។ ដោយន័យនេះ បុគ្គលអ្នកមានសទ្ធាបានសមាទានឧបោសថសីលប្រកបដោយអង្គ ៨ ប្រការ ឈ្មោះថាបានឡើងជាន់កាំថ្នាក់ទី ១ នៃ អដ្ឋង្គិកមគ្គ គឺអរិយមគ្គជារបស់បោចផុត ។

បុគ្គលគប្បីទំធ្វើសេចក្ដីស្ងប់រម្ងាប់ខាងផ្លូវចិត្ត ដែលជានាយបៅហ្វាយលើកាយនឹងវាចា ក៏អាចនឹងធ្វើឲ្យបរិសុទ្ធផល កាយកម្ម វចីកម្ម ទាំង មនោកម្ម ផងបានជាអនេកជាតិ ។

ប៉ុន្តែផ្លូវនេះពិបាកណាស់ ព្រោះជាផ្លូវដែលចិត្តធ្លាប់ត្រាប់បរទៅមក ៗ ជាច្រើនជាតិណាស់មកហើយ តែគង់មានគេធ្វើបាន មិនបាច់រាប់ហានៈឡើយ ។

ដើម្បីនឹងផ្លូវវិជ្ជសង្សារឲ្យផុត តាមជំនឿរបស់ពួកបណ្ឌិតពុទ្ធសាសនាសំដែងប្រាប់ថា បុគ្គលអ្នកបំពេញឧបោសថសីលប្រកបដោយអង្គ ៨ ត្រូវបំរើន កម្មដ្ឋាន ជាបទ សមាធិ កាលបើសមាធិកើតឡើងហើយ ក៏អាចនឹងដឹងនូវរសនៃកម្មដ្ឋាន ដែលបានឈ្មោះថា សមថភាវនា ជាដើម ។

ឯការប្រតិបត្តិតាមគុណធម៌ទាំងនេះ ជាគ្រឿងនាំចិត្តទៅកាន់សុជីវិភាពនៃមនុស្ស ឲ្យមានការរស់នៅដោយសុខស្រួលបាន ។

ប៉ុន្តែបុគ្គលដែលខំសមាទានឱ្យបោសបសីល មិនមែនមានសេចក្ដីប្រាថ្នាសុខតូចទេ គឺប្រាថ្នាសេចក្ដីសុខធំ បំពោះព្រះនិព្វាន ។ តែត្រូវមានការប្រយ័ត្នចិត្ត ។ លក្ខណៈរបស់ចិត្ត ចិត្តដែលត្រូវទោសគ្របសង្កត់បានហើយ បើមិនទប់ទេបណ្ដោយឱ្យកើតទៅតាមអំណាចរបស់ទោស ចិត្តនោះនឹងបង្គាប់មកលើកាយ នឹងវាចា ឱ្យធ្វើការអាក្រក់គ្រប់យ៉ាងរកទីបំផុតគ្មាន ។

មានការបៀតបៀនខ្លួនឯង នឹងអ្នកដទៃឱ្យបានសេចក្ដីវិនាសខូចកេរ្តិ៍ឈ្មោះ អន្តរាយអស់ទ្រព្យសម្បត្តិនឹងតាំងខ្លួនទុកនៅលែងមិនបាន អន្តរធានខូចជាតិកំណើតក្នុងជាតិនេះនឹងជាតិខាងមុខ បើខ្លួននឹងបានសុខខ្ពង់ខ្ពស់ ក៏បាបនោះទាញខ្លួនម្នាក់មកទាប ឱ្យចិត្តជាប់លិចលង់នៅតែក្នុងអន្លង់ទុក្ខ-ទោសគ្រប់មុខជាផលកើតឡើងពីចិត្តបាបនោះ ជាអនេកប្បការនឹងរាប់ពុំបានឡើយ ។

បុគ្គលអ្នករក្សាសីល ត្រូវប្រយ័ត្នចិត្ត តាំងចិត្តសង្រួម

រវាំងសីល ទុកដោយការកោតក្រែងខ្លាចដាច់សីល ខ្លាចសៅហ្មងសីល, ឯការដែលរក្សាសីល ឲ្យបានជាសីលប្រសើរ សីលបរិសុទ្ធស្អាតផូរផង់ល្អនោះ ត្រូវដឹងលក្ខណៈនៃសិក្ខាបទនោះ ៗ ទុកជាផ្លូវប្រតិបត្តិ ត្រូវរក្សាមិនឲ្យដាច់ពព្រុះពពាលសៅហ្មងធ្លុះធ្លាយដាច់សីលនោះឡើយ ព្រះអានព្រះភាគទ្រង់ត្រាស់ទុកក្នុង សាមញ្ញផលសូត្រ ថា សីលមិនមែនកំណាត់ សីលមិនមែនដាច់ សីលមិនមែនធ្លុះ មិនមែនពព្រុះ មិនមែនពពាល ទើបហៅថាសីលបាន ។

ឯចំណាត្តសីលមែនៗនោះ គឺចេតនាបរិសុទ្ធស្អាតផូរផង់ល្អ ពុំមានកិលេសតណ្ហាមានៈទិដ្ឋិពាល់ត្រូវឡើយ ឯចិត្តដែលបរិសុទ្ធហើយនោះ នឹងកើតទៅជាសមាធិ ។ល។

ការរក្សាសីលបានដូចន័យនេះ ទើបថាជាការរក្សាសីលប្រសើរ ហៅថា អរិយកន្តសីល បើកើតមានឡើងក្នុងចិត្តបានមួយខណៈ ១ គ្រា ក៏ឈ្មោះថាកើតបុណ្យហើយជាកុសលយ៉ាងជាន់ខ្ពស់ ។

ព្រលឹងខ្មែរ www.ameriquekhmere.fr

ទី ១ អ្នករក្សាសីល បើធ្វើឲ្យសីលដាច់ខាងដើម ឬ ខាងចុង ឈ្មោះថាសីលកំណាត់ ដូចជាកំណាត់ឈើដែលគេកាត់ដាច់ជាកំណាត់ៗនោះឯង ។

បើរក្សាសីលឲ្យដាច់ត្រង់កណ្ដាល ឈ្មោះថាសីលធ្លុះ ដូចក្អមធ្លាំងធ្លុះ, បើរក្សាសីលធ្វើឲ្យកន្លងពុំត្រូវអង្គកងសិក្ខាបទនោះៗ ទេឈ្មោះថា សីលពពាល សីលដាង សីលពពាល សីលពព្រុះដូចគោដាង គោពពាល គោពព្រុះនោះៗ ដែរ ។

ទី ២- អ្នករក្សាសីល បើធ្វើសីលឲ្យបរិសុទ្ធផុតពាកសៅហ្មងជាសីលពេញអង្គបរិបូរណ៍ផូរផង់ជានិច្ច ឈ្មោះថាសីលពិត នឹងកើតទៅជាសមាធិ គឺសីលនោះជាបាទរបស់សមាធិ ព្រោះសមាធិ ដែលនឹងកើតឡើងតាំងនៅដោយល្អបានផលកើតអានិសង្សនោះ ត្រូវអាស្រ័យសីលជាបាទ គឺជាជើងឲ្យសមាធិស្ថិតនៅបាន ។

ទី ៣ សេចក្ដីអធិប្បាយមកនេះ ទុកជាការដះទឿនក្រើនរំលឹកដល់លោកអ្នករក្សាសីលហើយសង្ឃឹមយកផល ត្រូវខំរក្សាកុំ

ឲ្យល្មើសកុំឲ្យដាច់ កុំឲ្យធ្លុះ កុំឲ្យពព្រុះ កុំឲ្យពពាល កុំឲ្យសៅហ្មងឡើយ ត្រូវតាំងសីលទុកជាទីគោរពយ៉ាងខ្ពស់ផុត ( កាម្ម ៗ៩ ១០)ៗ ត្រង់ន័យនេះ បណ្ឌិតលោកពោលថា បុគ្គលប្រដៅអ្នកដទៃមិនក្រដូចប្រដៅខ្លួនឯងទេ, ទោសអ្នកដទៃឃើញបានដោយងាយ ទោសរបស់ខ្លួនឃើញបានដោយកម្រ,

ហេតុនេះ ពួកជនជាបណ្ឌិត លោកពេញចិត្តនឹងប្រដៅខ្លួន ទូន្មានខ្លួនពេកជាមុនបានហើយ ទើបប្រដៅអ្នកដទៃដោយសេចក្តីសង្គ្រោះជាក្រោយ ។ល។

សីលធម៌នេះ ទុកដូចជាគ្រូអាចារ្យប្រដៅទូន្មានសិស្សឲ្យប្រព្រឹត្តល្អក្នុងកងសីលធម៌នេះឯង ។

ឯបណ្តាកុសលធម៌ទាំងអស់ លោកទុកសីលជាកំពូលធម៌ដ៏ខ្ពង់ខ្ពស់, ព្រោះសីលជាប្រធាន ឬជាបាទ ឬ ក៏ជាផែនដីសម្រាប់បណ្តុះពូជកុសលធម៌ទាំងពួង, សីលជាទឹកថ្លាសម្រាប់លាងមន្ទិលគឺកិលេសឲ្យស្អាតបានផង ជាទឹកសម្រាប់ស្រោចស្រប់លើសន្តានបិត្តសត្វ ដែលកំពុងក្តៅដោយភ្លើងទុក្ខ ភ្លើង

ព្រលឹងខ្មែរ www.ameriquemagazine.fr

កិលេសឲ្យត្រជាក់បានផង សីលជាគន្ធជាតិអប់រំសង្ឃឲ្យមានខ្លិនក្រអូបផ្សាយប្រះខ្យល់ទៅគ្រប់ទសទិសនានាបានផង សីលជាជណ្ដើរជាន់ឡើងទៅកាន់សមាធិផង ព្រោះន័យនេះបុគ្គលអ្នករក្សាសីល ត្រូវមានឧបាយគេចកែឲ្យផុតពីសេចក្ដីអន្តរាយដល់សីល បីដូចជាសត្វបក្សី ត្រដេវវិចរក្សាពងដោយឧបាយ ត្រូវស្រឡាញ់សីល បីដូចជាបុគ្គលស្រឡាញ់កូនតូចដែលខ្លួនមានតែ ១ ត្រូវរក្សាសីលដោយប្រយ័ត្ន បីដូចជាបុគ្គលរក្សាភ្នែកខ្លួនមានតែម្ខាងយ៉ាងណា យ៉ាងនោះដែរ ; សំដែងមកក្នុងសីលធម៌ជាគោលការសង្ខេបខ្លីៗ

ព្រលឹងខ្មែរ www.ameriquemagazine.fr

បប់សេចក្ដីតែប៉ុណ្ណេះៗ

*ថ្ងៃអង្គារ ១៤ កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥០៤ គ.ស. ១៩៦១*

ព្រះអតីតវិន័យធរ «ធម្មិស្សរោ» ឯក-ញឹម

អ្នកឧបត្ថម្ភ កោះតុម្ព

រោងពុម្ព គីម គី បណ្ណាគារ
លេខ៤៤ វិថីតេជោដំឌិន.ភ្នំពេញ